**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខ: ១១៨
ចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ ២០០៤
**សាលដីកា**
លេខ: ១៩៣
ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ២០០៤

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**
បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ ២០០៤ ដោយមានសមាសភាពដូចតទៅ:
១-ឯកឧត្តម ............ ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ
២-លោក .............. ជាចៅក្រម
៣-លោក ............ ជាចៅក្រម
៤-លោក ............. ជាចៅក្រមរបាយការណ៍
៥-លោក .............ជាចៅក្រម

**ក្រឡាបញ្ជី**
-កញ្ញា ................

**តំណាងមហាអយ្យការ**
-លោក .............. ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខពីសាលដីកា ៧៦(ក) ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ ២០០៣ នៃសំណុំរឿងរដ្ឋប្បវេណី លេខ៦៣៦ ចុះថ្ងៃទី ០១ ខែតុលា ឆ្នាំ ២០០៣ របស់សាលាឧទ្ធរណ៍ រវាង:

- ដើមចោទឈ្មោះ អអរក្នុងបណ្តឹងសាទុក្ខ ភេទប្រុស អាយុ ៤៣ឆ្នាំ ជាតិខ្មែរ មុខរបរស្ថានីយ៍បូមទឹកពន្លឺអរុណ ទីលំនៅសព្វថ្ងៃ ផ្ទះលេខ ២៤៨Eo ផ្ទះលេខ ១០៧ សង្កាត់បឹងព្រលិត ខ័ណ្ឌ៧មករាក្រុងភ្នំពេញ ។ ឪពុកឈ្មោះ អ៊ូច អ៊ឹម (រស់) ម្តាយឈ្មោះ អេង យ៉េន។ (រស់)ប្រពន្ធឈ្មោះ វង់ សុជា ។

- និងចុងចម្លើយឈ្មោះ មមភេទប្រុស អាយុ ៤៤ឆ្នាំជាតិខ្មែរ មុខរបរ ធ្វើស្រែទីលំនៅភូមិដង្កោម ឃុំកំពុងអុស ស្រុកពញាឮ ខេត្តកណ្តាល ។ ឪពុកឈ្មោះ ឃឹម ម៉េត ( ស្លាប់) ម្តាយឈ្មោះ ចក់ រ៉ី (រស់) ប្រពន្ធឈ្មោះ សុ ជាត ។

**<u>អំពីវិវាទ :</u>** ប្តឹងទាមទារប្រាក់

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ១១៨ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៤ របស់តុលាការកំពូល ។

បានឃើញបណ្តឹងសាទុក្ខលេខ ៤០ មុនថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០៤ របស់លោក មមមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៧៦(ក) ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៣ របស់សាលាឧទ្ធរណ៍លើ ត្រង់ចំណុចនៃសេចក្តីសម្រេចទំងមូល ។

តាមពាក្យបណ្តឹង ចុះថ្ងៃទី ២១-០១-២០០៣ របស់លោក អ៊ូច អ៊ុមរុន ប្តឹងទារប្រាក់ និងសុំឱ្យគោរពកិច្ចសន្យា ចុះថ្ងៃទី ២៦-០៩-១៩៩៩ និង កិច្ចសន្យា ចុះថ្ងៃទី ២៧-០៩-៩៩ ដែលចុងចម្លើយ មិនគោរពកិច្ចសន្យានិង បង្កមហន្តរាយដល់ស្ថានីយ៍បូមទឹក ពន្លឺអរុណ ។

បានឃើញ សាលក្រមរដ្ឋប្បវេណី លេខ ១៧ (ក) ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០៣ របស់តុលាការខេត្តកណ្តាល ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១- ទទួលពាក្យបណ្តឹង ចុះថ្ងៃទី ២១-៧-២០០២ និង ចុះថ្ងៃទី ២១-០១-២០០៣ របស់ឈ្មោះអ៊ូច អ៊ុំមុន ទុកជាត្រឹមត្រូវតាមទម្រង់ និង យកមកចាត់ការតាមច្បាប់ ។

២- រំលាយកិច្ចសន្យាចុះថ្ងៃទី ២៦-៩-១៩៩៩ និងកិច្ចសន្យាចុះថ្ងៃទី ២៧-០០៩-១៩៩៩បោលជាអសារបង់ ។

៣- ទទួលស្គាល់ការគ្រប់គ្រងកាន់កាប់ប្រើប្រាស់អាងទឹក ដែលបានជីករួចហើយនិងទបណ្តោតចែក ថាយទឹក របស់ឈ្មោះ អ៊ូច អ៊ុំមុន និង ឱ្យឈ្មោះ អ៊ូច អ៊ុំមុន បន្តការបូមទឹកចែកជូនប្រជាជន ជាបណ្តោះអាសន្ន រហូតដល់មានកិច្ចសន្យាថ្មីកើតមានឡើង ។

៤- បង្គាប់ឱ្យឈ្មោះ មមសងប្រាក់ថ្លៃខូចខាតប្រព័ន្ធប្រឡាយទឹក និង ការខូចខាតផលស្រូវ ចំនួន ១០.០០០.០០០រៀល (ដប់លានរៀល) សំណើលើសពីនេះ លើកចោល ។

ក្នុងករណីគ្មានប្រាក់សងគ្រប់ចំនួន ត្រូវរឹបអូសទ្រព្យសម្បត្តិលក់ឡាយឡុង បើរឹងទទឹងត្រូវដាក់គុកបង្ខំដល់រូបកាយ តាមមាត្រា ១៣៣ នៃច្បាប់ស្តីពីការអនុវត្តសាលក្រមរដ្ឋប្បវេណី ។

៥- រឹបអូសប្រាក់ប្រដាប់ក្តីសរុប ១៤០០០រៀល លើពន្ធចុះបញ្ជីក្តីនិងពន្ធហ្នឹង ៣៦០០រៀល រង្វាន់ ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤០០រៀល រង្វាន់ប្រគល់ដីកាកោន ចំនួន ១០.០០០ រៀល ប្រាក់នេះដើមចោទបានបង់ រួចហើយ ។

៦- សាលក្រមនេះ ប្រកាសជាសាធារណៈចំពោះ មុខដើមចោទឈ្មោះ អ៊ូច អ៊ីមុន និង ចុងចម្លើយឈ្មោះ មម។

បើកផ្លូវប្តឹងឧទ្ធរណ៍ រយៈពេល២ខែ តាមកំណត់ច្បាប់ ។

បានឃើញ បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ ២០០៣ របស់លោក មមមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ១៧(ក)ចុះថ្ងៃទី២៧ខែឧសភា ឆ្នាំ ២០០៣ របស់តុលាការខេត្តកណ្តាលលើត្រង់ចំណុចទី៣ និងទី៤ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៧៦(ក) ចុះថ្ងៃទី១៨ ខែ ធ្នូ ឆ្នាំ ២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០៣-០៦-២០០៣ របស់លោក គង់ សុភ័ក្រ្ត ជាមេធាវីការពារក្តីឱ្យឈ្មោះ មមទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់ខុសនឹងគតិច្បាប់។

២- តម្កល់សាលក្រមរដ្ឋប្បវេណីលេខ១៧(ក) ចុះថ្ងៃទី ២៧-០៥-២០០៣ ទុកជាបានការដដែល តែកែតម្រូវចំណុចទី២ នៃសាលក្រមថា លប់ចោលតែកិច្ចសន្យារវាងដើមចោទ និង ចុងចម្លើយ មិនទាក់ទងដល់កិច្ចសន្យានៃប្រជាជនផ្សេងៗ ទៀតទេ ។

៣- កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន ១៣០០០រៀល ដែលដើមចោទឈ្មោះ អ៊ូច អ៊ុំមុន បានបង់ជួសរួចហើយ គឺពន្ធហ្នឹងនិងពន្ធចុះបញ្ជីក្តី ២៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០រៀល ចំណាយលើអ្នកប្រគល់ដីកាកោះ និង អាជ្ញាធរតុលាការចំនួន ១០.០០០រៀល សរុប ១៣០០០រៀល ។

៤- សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខគូក្តី និងចំពោះមុខមេធាវី បើក ផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញ បណ្តឹងសាទុក្ខលេខ ៤០ ចុះថ្ងៃទី២៨ ខែ មករា ឆ្នាំ២០០៤ របស់លោក មមមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៧៦(ក) ចុះថ្ងៃទី ១៨ ខែ ធ្នូឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ លើត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញ សារណាការពារ ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០៤ របស់លោក មម

បានឃើញ សារណាតបចុះថ្ងៃទី២៧ ខែ មេសា ឆ្នាំ ២០០៤ របស់លោក អ៊ូច អ៊ុមរុន

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការថា ៖

- សាលដីការបស់សាលាឧទ្ធរណ៍ បានសម្រេចមានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះ ពិនិត្យ សម្រេចតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់ លោក មមបានឆ្លើយថា ខ្លួនមិនសុខចិត្តនឹងការសម្រេចរបស់សាលាឧទ្ធរណ៍ ដែលបានសម្រេចឱ្យលោក អ៊ូច អ៊ីមន នោះឈ្នះ ហើយពេលជំនុំជំរះនោះ មានភាគីដើមចោទតែម្ខាងទេ។ នៅពេលដាក់ទឹកនោះ លោក អ៊ូច អ៊ុមរុន ពុំព្រមមកបូមទឹកដាក់អាងទេ ហើយអាងទឹកនេះ គឺជាអាងទឹកចាស់ តាំងពីយូរយារណាស់មកហើយ ចំពោះអ្នកកប់បំផ្លាញអាងទឹកនោះ គឺប្រជាជនជាអ្នកកាប់ទេ ពុំមែនខ្លួនជាអ្នក កាប់ទេ ។ សព្វថ្ងៃនេះ ប្រជាជនរងទុក្ខវេទនាខ្លាំងណាស់ ដោយពុំបានបូមទឹកដាក់អាងនេះទេ ធ្វើឱ្យស្រូវប្រជាជន ត្រូវងាប់អស់គ្មានសល់ ។ ខ្លួនបានធ្វើកិច្ចសន្យាជាមួយលោក អ៊ូច អ៊ុមរុន នេះ គឺខ្លួនតំណាងឱ្យប្រជាជនទាំងអស់ មុនធ្វើកិច្ចសន្យាដាក់ទឹកនេះ លោក អ៊ូច អ៊ីមន បានសន្យាថា យកតែថ្លៃប្រេងពីខ្លួនម្នាក់ទេ ឯអ្នកផ្សេងក្រៅពី ខ្លួននោះគឺត្រូវបង់ស្រូវតម្លៃ ៤០ ថាំង ក្នុង១ហិកតា ។ ខ្លួនបានសងលុយគាត់ចំនួន១១លានរៀលរួចហើយ ។ ក្នុងកិច្ចសន្យាបានចែងថា បើស្អកត្រូវម្ចាស់ស្ថានីយ៍បូមទឹកជាអ្នកចេញសង ហើយគាត់បាននិយាយថាឱ្យតែសងលុយគាត់អស់ និងឈប់ប្តឹងផ្តល់ទៅគាត់នឹងរំលាយកិច្ចសន្យានេះចោលហើយ ។

សូមឱ្យតុលាការជួយរកយុត្តិធម៌ និង ដោះស្រាយតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់លោក អ៊ូច អ៊ុមរុន បានឆ្លើយថា ជាការពិតណាស់ដែលខ្លួនបានយកថ្លៃដាក់ទឹក១ហិចតា ចំនួន ៤០ថាំង ស្មើនឹង ៤០០០០០រដែរ លុយនេះបានចចារគ្នាត្រូវរ៉ូវគ្នា ហើយក៏បានដកពាក្យបណ្តឹងវិញ និង បានសងលុយរួចហើយដែរ ហេតុអ្វីក៏គាត់យកម៉ាស៊ីនតូច១ មកដាក់ ចំពោះបញ្ហាបូមទឹក ដាក់អាង ដើម្បីធ្វើស្រែជាច្រើននេះ គឺវាមិនអាចតម្រូវការឱ្យស្រែទាំងនោះបានទេ ។ ដោយមានពាក្យបណ្តឹងរបស់ ប្រជាជន និង មានគណៈកម្មការភូមិ ឃុំប្រជុំសុំទឹកខ្លួននោះ ក្រោយមកក៏មានដីកាចាប់ខ្លួន ម៉េត មិត ទៀតក្នុងការដែលនាំបក្សពួកកាប់បំផ្លាញអាងទឹក និងទទឹកចែកចាយ ថែមទាំងយកម៉ាស៊ីនតូចៗ ទៅដាក់លើស្ថានីយ៍របស់ខ្លួន ហើយគំរាមកំហែងខ្លួន មិនឱ្យម៉ាស៊ីនរបស់ខ្លួនដំណើរការបូមទឹកដាក់ស្រូវបានទៀត ។

- តាមសំដីរបស់លោកម៉េតមិតនេះខ្លួនសូមបដិសេធចំពោះបញ្ហា ដែលខ្លួនធ្វើឱ្យស្អកស្រូវប្រជាជននោះ ខ្លួនពុំបានធ្វើទេ គឺមានតែខ្លួនលោក ម៉េត មិត ទេ ជាអ្នកប្រព្រឹត្តនោះ ។

- ចំពោះការលុបកិច្ចសន្យានេះ ចោលនោះ គឺត្រូវធ្វើកិច្ចសន្យាថ្មីទៀត ដោយយោងទៅលើសាលក្រម ។

សូមតុលាការកំពូលជួយរកយុត្តិធម៌ឱ្យខ្លួនផង ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៤០ ចុះថ្ងៃទី២៨ខែ មករា ឆ្នាំ២០០៤ របស់ឈ្មោះ ម៉េត មិត ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការលើកឡើងរបស់ឈ្មោះ ម៉េត មិត ក្នុងសារណា ចុះថ្ងៃទី១៩ខែមេសាឆ្នាំ២០០៤ថាកិច្ចសន្យារកស៊ីនោះត្រូវអស់សុពលភាពហើយ គឺឈ្មោះ អ៊ូច អ៊ីមរុន ពុំមានតួនាទីអ្វីផ្គត់ផ្គង់ទឹកនៅតំបន់នោះទៀតទេ ដោយកិច្ចសន្យារំលាយអស់ហើយ។ ការលើកឡើងនេះមិនត្រឹមត្រូវឡើយ ពីព្រោះការរំលាយ កិច្ចសន្យានេះ ធ្វើឡើងចំពោះតែចុងចម្លើយនិងដើមចោទប៉ុណ្ណោះ មិនទាក់ទងជាមួយកិច្ចសន្យានឹងប្រជាជនផ្សេងៗទេ ។

- យល់ឃើញថា ស្ថានីយ៍បូមទឹក ប្រឡាយជាកម្មសិទ្ធិរបស់លោក អ៊ូច អ៊ីមរុន ពិតជាត្រូវបានខូច ខាតដោយសារសកម្មភាពរបស់ចុងចម្លើយ និងបក្សពួករបស់ខ្លួនប្រាកដមែន ។ ដូច្នេះចុងចម្លើយត្រូវតែចេញសង នូវព្យសនកម្មនេះ ។

- យល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ប្រាក់ ១១លានរៀល ដែលលោក ម៉េត មិត បានប្រគល់ឱ្យលោក អ៊ូច អ៊ីមរុន គឺជាប្រាក់ជំពាក់ថ្លៃបូមទឹកដាក់ស្រែ ដែលលោក ម៉េត មិត បានបូមទឹកនេះដាក់ ស្រែហើយបន្ទាប់ពីប្រមូលផលរួចមិនព្រមសងឱ្យដើមចោទ ។ ដោយឡែកប្រជាជន៨៧ គ្រួសារ ទៀត បានសង រួចរាល់ ដោយផ្ទាល់ជាមួយដើមចោទហើយ។ លោក ម៉េត មិត ក៏បានទទួលស្គាល់បញ្ហានេះ នៅមុខតុលាការដែរ។ ដូច្នេះពុំមានភស្តុតាងណាថា ដើមចោទទទួលប្រាក់ ១១លានរៀល ជាថ្លៃជាមួយអាងទឹក និងទទឹកដាក់ស្រែដែល ដើមចោទសាងសង់និងចំណាយអស់ប្រាក់ជាច្រើនម៉ឺនដុល្លាអាមេរិកនោះ ឱ្យទៅលោក ម៉េត មិត្តទេ ។ ហេតុនេះ ដើមចោទពុំត្រូវបានបាត់បង់សិទ្ធិលើទទឹក និង អាងទឹក ដែលជាប្រភពផ្តល់ទឹកជូនពលរដ្ឋធ្វើស្រែប្រាំងនោះទទេ ។

- យល់ឃើញថា ចុងចម្លើយលោក ម៉េត មិត និង ជនដទៃទៀត នៅតែមានសិទ្ធិធ្វើកិច្ចសន្យាប្រើប្រាស់ទឹកនេះបន្តទៀតពីដើមចោទដដែល ពុំមានបណ្តាលឱ្យបាត់បង់ផលប្រយោជន៍អ្នកប្រើប្រាស់ទឹកសម្រាប់ធ្វើស្រែ ប្រាំងរបស់ខ្លួនទេ ។

- យល់ឃើញថា ពុំមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ការខូចខាតផលដំណាំរបស់ម្ចាស់ស្រែកន្លងមកបណ្តាលមកពីកំហុសរបស់ដើមចោទ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៧៦ (ក) ចុះថ្ងៃទីទី១៨ខែធ្នូ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ហើយ ។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្តី ចំពោះមុខគូក្តី

១- ទទួលបណ្តឹងសាទុក្ខលេខ ៤០ ចុះថ្ងៃទី២៨ ខែ មករា ឆ្នាំ ២០០៤ របស់ឈ្មោះ ម៉េត មិត ទុក ជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ ៧៦(ក) ចុះថ្ងៃទី ១៨ ខែ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទំងមូល ។

៣- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩០០០រៀល ដែលលោក អ៊ូច អ៊ុមរុន បានបង់ជួសនៅតុលាការ កំពូលរួចហើយ គឺ

- ពន្ធចុះបញ្ជីក្តីនិងពន្ធហ្នឹងចំនួន៤០០០រៀលប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀលសម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់,

- ចំណាយលើកិច្ចប្រគល់ដីកាកោះ ចំនួន១៥០០០រៀល សរុប១៩០០០រៀល ហើយតម្រូវឱ្យឈ្មោះ ម៉េត មិត សងប្រាក់១៩០០០៛ នេះ ទៅលោក អអរវិញ ។

បង្គាប់ឱ្យចុងចម្លើយបង់ពន្ធសមាមាត្រ១%លើទឹកប្រាក់ដែលត្រូវសងដើមចោទ ។

៤- សាលដីកានេះ ជំនុំជំរះនៅថ្ងៃទី០៦ខែកញ្ញា ឆ្នាំ២០០៤ និង ប្រកាសនាសវនាការជាសាធារណៈ ។